# 소망의 여인들

## Prayer Calander

2024년 6월

ប្រតិទិនអធិស្ឋានចេញផ្សាយជារៀងរាល់ខែ ដែលមានជាង 100ភាសា និងមានអ្នកចូលរួមអធិស្ឋានជាង 110,000នាក់



**ការអធិស្ឋានសម្រាប់ស្ត្រីអាស៊ី 2**

តើយើងអាចរស់នៅដោយមានភាពបរិសុទ្ធយ៉ាងដូចម្តេចបើ
យើងនៅឆ្ងាយពីព្រះជាម្ចាស់?
ពេលដែលយើងឃើញអំពើបាបរបស់យើងតាមរយៈព្រះនេត្ររប
ស់ព្រះ ដួងចិត្តរបស់យើងពិតជាខ្ទិចខ្ទាំ។
យើងអរព្រះគុណទ្រង់ដែលបានអត់ទោសឱ្យយើង
ស្រឡាញ់យើង ហើយបានសង្គ្រោះយើង
ដើម្បីអោយយើងបានរស់នៅដាច់ដោយឡែក
ហើយអនុញ្ញាតឱ្យទ្រង់គ្រប់គ្រងដួងចិត្ត និងគំនិតរបស់យើង
នៅពេលដែលយើងប្រគល់ដួងចិត្ត
និងគំនិតរបស់យើងទៅចំពោះទ្រង់ដូចរៀងរាល់ថ្ងៃដែលយើង
ធ្វើនេះ នោះទ្រង់នឹងចាប់ផ្តើមធ្វើការ
ហើយផ្តល់ឱ្យយើងនូវកម្លាំង
និងការយល់ឃើញដើម្បីជ្រើសរើសផ្លូវដែលត្រឹមត្រូវ
និងតាមព្រះទ័យរបស់ទ្រង់។
អ្នកអាចធ្វើតាមព្រះហរទ័យរបស់ទ្រង់ដោយធ្វើវាម្តងមួយៗ។

카카오톡 채널에서 '소망의 여인들' 채널을 추가하시면
매주 월요일에 한국어 기도카드를 받으실 수 있습니다.

1. បិតាអើយ អត្រានៃអក្ខរកម្មនៅប្រទេសវៀតណាមនៅតែមានកម្រឹតខ្ពស់។ យើងអធិស្ឋានថាស្ត្រីនៅក្នុងប្រទេសកំពុងអភិវឌ្ឍន៍នេះនឹងមានឱកាសកាន់តែច្រើនក្នុងការរៀនអាន និងសរសេរ។ (នេហេមា ៨:៨)

2. ព្រះជាម្ចាស់អើយ សូមព្រះអង្គប្រទានប្រាជ្ញា និងការយល់ឃើញដល់ព័ន្ធកិច្ចរបស់យើងនៅក្នុងប្រទេសកម្ពុជា ដើម្បីអោយពួកគេធ្វើការសម្រេចចិត្តដោយស្តាប់បង្គាប់ព្រះជាម្ចាស់។ សូមឱ្យពួកគេស្រឡាញ់ លើកទឹកចិត្ត និងគាំទ្រគ្នាទៅវិញទៅមក ហើយធ្វើជាពន្លឺនៅក្នុងសហគមន៍របស់ពួកគេ។ ( យ៉ូហាន ១៣:៣៥ )

3. យើងសូមសរសើរព្រះនាមទ្រង់ចំពោះម្ចាស់ជំនួយ និងអង់តែនវិទ្យុពី KTWR នៅលើកោះ Guam និងស្ថានីយ៍ក្នុងស្រុកចំនួន 80 ដែលអាចឱ្យស្ត្រីឥណ្ឌូនេស៊ីរាប់លាននាក់បានឮព្រះបន្ទូលរបស់ទ្រង់ និងទទួលបានការអប់រំអំពីបញ្ហាស្ត្រី។ (២កូរិនថូស ៩:៦-៧)

4. ព្រះអម្ចាស់អើយ
សូមទ្រង់ផ្តល់ឱ្យមានការបង្កើនឱកាសសេដ្ឋកិច្ចសម្រាប់ស្ត្រីនៅក្នុងប្រទេសនេប៉ាល់ រួមទាំងការងារ និងសហគ្រិនភាពដើម្បីអោយពួកគេអាចមានជំហរផ្នែកហិរញ្ញវត្ថុ។ (សុភាសិត ៣១:៨-៩)

5. បិតាអើយ
សូមឲ្យសេចក្តីពិតរបស់ទ្រង់នៅអំពីទំនាក់ទំនងអាពាហ៍ពិពាហ៍ត្រូវបានបង្រៀនជាភាសាម៉ុងហ្គោលី។ សូមអោយស្វាមីចេះស្រឡាញ់ និងគោរពភរិយា ហើយសូមភរិយាគោរព និងចុះចូលចំពោះស្វាមីផងដែរ។ (១ពេត្រុស ៣:១-៧)

6. ព្រះអម្ចាស់អើយ
សូមទ្រង់ជួយសម្រាលទុក្ខដល់អ្នកម្តាយដែលនៅលីវក្នុងប្រទេសហ្វីលីពីន ដែលកំពុងធ្វើការយ៉ាងលំបាកដើម្បីផ្គត់ផ្គង់នូវតម្រូវការរបស់កូនរបស់ពួកគេ។ (អេសាយ ៤១:១៣)

7. ព្រះអម្ចាស់អើយ យើងខ្ញុំសូមអធិស្ឋានឱ្យស្ត្រីនៅក្នុងប្រទេសប៉ាគីស្ថាន សូមអោយពួកគេបានរួចផុតពីការបៀតបៀននៅកន្លែងធ្វើការ ដែលការងាររបស់គេមិនសូវល្អ និងប្រាក់ឈ្នួលទាប ដែលជាលទ្ធផលនាំឱ្យពួកគេមិនអាចបន្តការងាររបស់ពួកគេបានទៀត។ (សុភាសិត ២២:២)

8. ព្រះវរបិតាអើយ
យើងអធិស្ឋានសម្រាប់សិស្សកូរ៉េខាងជើងដែលបានក្លាយជាគ្រិស្តបរិស័ទពេលកំពុងសិក្សានៅបរទេស។ សូមរក្សាសុវត្ថិភាពពួកគេនៅពេលពួកគេត្រឡប់មកផ្ទះវិញ សូមប្រើពួកគេដើម្បីផ្លាស់ប្តូរប្រទេសកូរ៉េខាងជើងផងដែរ។ (យ៉ូស្វេ ១:៩)

9. ព្រះជាអម្ចាស់ សូមប្រទានប្រាជ្ញាដល់រដ្ឋាភិបាលនៃប្រទេស Papua New Guinea ក្នុងការដែលពួកគេប្រយុទ្ធប្រឆាំងនឹងអំពើហិង្សា និងអស្ថិរភាព។ សូមឱ្យការនោះបានការពារស្ត្រី ប្រឆាំងនឹងការរំលោភដែលកំពុងកើនឡើងរាល់ថ្ងៃ។ (សុភាសិត ២:៦)

10. ព្រះអម្ចាស់អើយ សូមការពារ និងផ្គត់ផ្គង់គ្រួសារនៅក្នុងប្រទេសមីយ៉ាន់ម៉ា ដែលរងផលប៉ះពាល់ដោយជម្លោះយោធាដែលកំពុងបន្ត និងមានគ្រោះមហន្តរាយធម្មជាតិជាញឹកញាប់ផងដែរ។ (ណាហ៊ូម ១:៧)

11. បិតាអើយ
សូមនាំមកនូវការផ្លាស់ប្តូរក្នុងលក្ខខណ្ឌនៅក្នុងប្រទេសឥណ្ឌា ដែលមិនត្រឹមតែរួមចំណែកដល់អត្រាបោះបង់ការសិក្សាខ្ពស់ប៉ុណ្ណោះទេ ប៉ុន្តែក៏មានអត្រានៃមរណភាពរបស់ក្មេងស្រីខ្ពស់ជាងក្មេងប្រុសផងដែរ។ (សុភាសិត ១៨:១៥

12. ព្រះវរបិតាអើយ ជនជាតិជប៉ុនភាគច្រើនមិនជឿលើព្រះយេស៊ូវទេ ប៉ុន្តែពួកគេជឿលើព្រះនៃសាសនា Shintoism ។ សូមធ្វើឱ្យមានការផុសផុលដ៏អស្ចារ្យនៃការប្រែចិត្ត និងសេចក្តីជំនឿទូទាំងប្រទេសជប៉ុនឡើងវិញ បិតាអើយ។ (អេសាយ ៤៥:៥-៦)


**TWR Korea 북방선교방송**

서울특별시 관악구 양녕로 15, 월드빌딩 6층

전화 (02)886-5671 / 이메일 hskim@twrk.or.kr

13. ព្រះអង្គអើយ
សូមកែប្រែដួងចិត្តរបស់មនុស្សក្នុងការនាំមកនូវការផ្លាស់ប្តូរច្បាប់នៅប្រទេស
ម៉ាឡេស៊ី។ សូមឲ្យអាពាហ៍ពិពាហ៍កុមារ
និងអំពើហិង្សាយេនឌ័រត្រូវបានបញ្ចប់
ហើយអោយពួកគេទទួលបានប្រាក់ខែស្មើគ្នាផងដែរ។ (ភីលីព ២:១៣)

14. ព្រះអម្ចាស់អើយ ទូលបង្គំអធិស្ឋានថា
ស្ត្រីនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន
ដែលត្រូវបានហាមឃាត់មិនឱ្យមានការងារធ្វើ ចូលសាលារៀន
និងចូលកន្លែងសាធារណៈ
នឹងទទួលបានសិទ្ធិរបស់ពួកគេឡើងវិញម្តងទៀត។ (លោកុប្បត្តិ ១៦:១៣)

15. ស្ទើរតែ 20% នៃប្រជាជននៅក្នុងប្រទេសចិនមានអាយុ 60
ឆ្នាំឬលើសពីនេះ។ ឱព្រះវរបិតាអើយ យើងអធិស្ឋានសម្រាប់សុខភាពផ្លូវចិត្ត
និងសុខុមាលភាពរបស់ស្ត្រីចំណាស់ទាំងនោះនៅក្នុងប្រទេសចិន។

(ទំនុកតម្កើង ៤២:១១)

16. ព្រះជាអម្ចាស់អើយ សូមផ្តល់អំណាចដល់អ្នកជឿនៅប្រទេសសិង្ហបុរី
ដើម្បីពង្រីកអណាចក្ររបស់ទ្រង់ និងស្វែងរកកម្លាំង
និងសេចក្តីអំណររបស់ពួកគេនៅក្នុងទ្រង់ផងដែរ
ទោះបីពួកគេឆ្លងកាត់ការលំបាកក៏ដោយ។
សូមផ្គត់ផ្គង់តម្រូវការរបស់ពួកគេ។ (យ៉ាកុប ១:២-៤)

17. កូនសូមសរសើរតម្កើងព្រះនាមទ្រង់
មានស្ត្រីជាច្រើននៅក្នុងប្រទេសវៀតណាមនៅពេលនេះបានស្គាល់ព្រះយេស៊ូ
វ បន្ទាប់ពីពួកគេបានស្តាប់កម្មវិធីស្ត្រីក្នុងក្តីសង្ឃឹម
ហើយទទួលស្គាល់ថាពួកគេពិតជាមានតម្លៃនៅក្នុងព្រះនេត្ររបស់ទ្រង់។
(អេសាយ ៤៣:៤)

18. បិតាអើយ សូមឲ្យភរិយា
និងស្វាមីនៅប្រទេសហ្វីលីពីនរៀនមានការទាក់ទងគ្នាអោយបានល្អ
ដើម្បីពង្រឹងទំនាក់ទំនងរបស់ពួកគេ។
នាំឲ្យមានការផ្លាស់ប្រែចំពោះប្តីដែលស្រវឹងស្រា
និងការពារដល់ប្រពន្ធដែលត្រូវបានស្វាមីគេធ្វើបាបផងដែរ។ (ទំនុកតម្កើង ៥០:៥)

19. ព្រះអម្ចាស់អើយ សូមប្រទាននូវសុវត្ថិភាព និងការការពារពីអំពើហិង្សា
និងការរើសអើងដល់ស្ត្រីនៅក្នុងប្រទេសនេប៉ាល់។
សូមឲ្យពួកគេរកឃើញទំនាក់ទំនង ការចិញ្ចឹមបីបាច់
ការថែរក្សាដែលរួមចំណែកដល់សុខភាពអារម្មណ៍ និងផ្លូវចិត្តរបស់ពួកគេ។
(ទំនុកតម្កើង ៩១:៤)

20. សូមម្តាយ និងជីដូនដែលជាគ្រិស្តស្ទាននៅប្រទេសម៉ុងហ្គោលី
បានរឹងមាំក្នុងសេចក្តីជំនឿរបស់ពួកគេ និងធ្វើជាបន្ទាល់
នៅពេលពួកគេបង្រៀនណែនាំកូនចៅរបស់ពួកគេតាមព្រះបន្ទូល។
(២ធីម៉ូថេ ១:៣-៥)

21.នៅពេលដែលតម្លៃម្ហូបអាហារកើនឡើងយ៉ាងខ្លាំងនៅក្នុងប្រទេសឥណ្ឌូ
នេស៊ី មានគ្រួសារក្រីក្រជាច្រើនមានការលំបាកក្នុងការទិញអាហារ។
ព្រះអង្គអើយ សូមផ្គត់ផ្គង់តម្រូវការប្រចាំថ្ងៃរបស់ពួកគេ
ដើម្បីកុំឱ្យគ្រួសារទាំងនោះត្រូវអត់ឃ្លាននោះឡើយ។ (ភីលីព ៤:១៩)

22. ព្រះអម្ចាស់អើយ
ដោយសារភាពគ្មានកូនគឺជាបញ្ហាចម្បងសម្រាប់ស្ត្រីនៅប៉ាគីស្ថាន
សូមប្រទានពរដល់ពួកគេអោយមានកូន។
សូមឲ្យទារកដែលជាស្រីត្រូវបានទទួលដោយអំណរ
សូមកុំពួកគេត្រូវបានគេមើលឃើញថាជាបន្ទុកនោះឡើយ។ (ទំនុកតម្កើង
១២៧:៣)

23. បិតាអើយ
ពេលនេះមានការកើនឡើងយ៉ាងខ្លាំងនៃអំពើហឹង្សាក្នុងទំនាក់ទំនងស្នេហា
នៅក្នុងប្រទេសកូរ៉េខាងត្បូង សូមអោយបុរសរៀនគោរពស្ត្រី
ហើយសូមអោយការខឹងសម្បារ
និងហឹង្សារបស់ពួកគេត្រូវបានផ្លាស់ប្តូរតាមព្រះបន្ទូលរបស់ទ្រង់។
(២កូរិនថូស ៥:៧)

24. ព្រះអម្ចាស់អើយ សូមប្រទានឱ្យស្ត្រីនៅកម្ពុជាមានស្ថិរភាពហិរញ្ញវត្ថុ
តាមរយៈការងារ ការបណ្តុះបណ្តាលជំនាញ និងប្រាក់ឈ្នួលសមរម្យ។
សូមជួយពួកគេឱ្យគ្រប់គ្រងធនធានរបស់ពួកគេដោយភាពឆ្លាតវៃ។ (សាស្តា
៧:១២)

25. បិតាអើយ យើងស្វែងរក
និងអំពាវនាវអោយមានសុវត្ថិភាពសម្រាប់ស្ត្រីនៅក្នុងប្រទេសឥណ្ឌា
ដែលពួកគេងាយរងគ្រោះដោយឧក្រិដ្ឋកម្ម ជាពិសេសនៅតាមទីសាធារណៈ
ដូចជាផ្លូវក្រោមដី និងផ្លូវដែលបោះបង់ចោល។ (អេសាយ ២៥:៤)

26. ព្រះអង្គអើយ
សូមជួយជនដែលរងគ្រោះដោយរញ្ជួយដីនៅឧបទ្វីបណ្ដូតូប្រទេសជប៉ុន។
សូមជួយក្រុមជំនុំក្នុងការបម្រើដល់ជនរងគ្រោះទាំងនោះខាងរូបកាយ
និងខាងព្រលឹងវិញ្ញាណដើម្បីឲ្យពួកគេបានទទួលការសង្គ្រោះមកពីទ្រង់។
(ទំនុកតម្កើង ១២១:១-២)

27. យើងសរសើរតម្កើព្រះនាមទ្រង់ចំពោះភាពជាដៃគូរបស់យើងជាមួយវិទ្យុ
Wantok នៅប្រទេស Papua New Guinea ។
សូមឲ្យព្រះវិញ្ញាណបរិសុទ្ធទ្រង់ប្រើកម្មវិធីស្ត្រីក្នុងក្តីសង្ឃឹមដើម្បីពង្រឹងសេចក្តី
ជំនឿអ្នកស្តាប់ដែលតស៊ូនឹងការល្បួងផងដែរ។ (ម៉ាថាយ ២៦:៤១)

28. ព្រះជាអម្ចាស់ សូមនាំមកនូវសន្តិភាព
និងការព្យាបាលដល់ស្ត្រីនៅក្នុងប្រទេសអាហ្វហ្គានីស្ថាន
ដែលបានបាត់បង់សមាជិកគ្រួសារ
និងទ្រព្យសម្បត្តិនៅក្នុងការរញ្ជួយដីនៅឆ្នាំ 2023 ។ (ភីលីព ៤:៧-៩)

29. ព្រះអម្ចាស់អើយ សូមពង្រឹង និងការពារស្ត្រីជនជាតិចិន
ដែលបានជួបប្រទះនឹងអំពើហិង្សាផ្លូវកាយ និងផ្លូវចិត្តពីប្តីរបស់ពួកគេ។
សូមអោយប៉ូលិសបញ្ឈប់ក្នុងការចាត់ទុកករណីហិង្សានេះជាហិង្សាក្នុងគ្រួ
សារនោះឡើយ។ (២សាំញ៉ូអែល ២២:៤៩)

30. ព្រះវរបិតាអើយ
សូមប្រទានពរដល់ផែនការនៃក្រុមការងារស្ត្រីក្នុងក្តីសង្ឃឹមនៅក្នុងប្រទេស
ម៉ាឡេស៊ី
ក្នុងការផ្តល់នូវបន្ទះអនាម័យដោយឥតគិតថ្លៃដល់អ្នកដែលមិនមានលទ្ធភា
ពទិញ។ (ចោទិយកថា ១៥:៧-៨)

**후원안내**
**국민은행 851-01-0003-724 북방선교방송**
**최초 입금 후 사무실로 연락주시기 바랍니다.**